**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៥៩...០១៨...១២៣...ធ.ន.ក

ថ្ងៃអង្គារ ១៣រោច ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដកហូតអាជ្ញាប័ណ្ណអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ

ធនាគារជាតិនៃកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជន ក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធឱ្យបានជ្រាបថា កាលពីថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំរកា នព្វស័កព.ស. ២៥៦១ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជាបានសម្រេចដកហូតអាជ្ញាប័ណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃរបស់ក្រុមហ៊ុនចំនួន១០ ដោយសារក្រុមហ៊ុនមិនមានសកម្មភាពនាំចេញ-ចូលមាសក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ។ ក្រុមហ៊ុនដែលត្រូវបានដកអាជ្ញាប័ណ្ណមានរាយនាមដូចខាងក្រោម ៖

១- ក្រុមហ៊ុន **លីបឺធីហ្គោល( ខេមបូឌា ) អ៊ីមផត អិចផត** ( LIBERTY GOLD (CAMBODIA) IMPORT EXPORT Co.,Ltd ) អាជ្ញាប័ណ្ណលេខ មជល០១/១០ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០

២- ក្រុមហ៊ុន **ហ្វឺសស្តេតហ្គោល អិនវេសមេន** ( FIRST STATE GOLD INVESMENT Co.,Ltd ) អាជ្ញាប័ណ្ណលេខ ០០៦/០១០ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០

៣- ក្រុមហ៊ុន **វិមានសិលាអិលធីឌី** ( VIMEAN SEILA LTD ) អាជ្ញាប័ណ្ណលេខ ០០៧/០១០ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០

៤- ក្រុមហ៊ុន **រ៉ូយ៉ាល់ ហ្គោល (ខេមបូឌា) អិនវេសមេន** ROYAL GOLD ( CAMBODIA INVESTMENT Co.,Ltd ) អាជ្ញាប័ណ្ណលេខ ០០៣/០១១ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១១

៥- ក្រុមហ៊ុន **អាស្កាព ហ្គោល អិនវេសមេន** ( ASKAP GOLD INVESTMENT Co.,Ltd ) អាជ្ញាប័ណ្ណលេខ ០០២/០១២ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២

៦- ក្រុមហ៊ុន **អេហ្វយូជីអាយ ហ្គោល** ( F U G I GOLD.,Ltd ) អាជ្ញាប័ណ្ណលេខ ០០៣/០១២ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២

៧- ក្រុមហ៊ុន **ជេភីអេ អឹសូស៊ីអេត ខូអិលធីឌី** (J P A ASSOCIATES Co.,Ltd ) អាជ្ញាប័ណ្ណលេខ ០០៤/០១២ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១២

៨- ក្រុមហ៊ុន **ខ្មែរ ហ្គោល ស៊ីលវើខន អិនវេសមេនលីមីធីត** (KHMER GOLD & SILVER COINS INVESTMENT Ltd ) អាជ្ញាប័ណ្ណលេខ ០០៣/០១៤ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤

៩- ក្រុមហ៊ុន **ហ្គោលខ្វេស ខូអិលធីឌី** (GOLD GUEST.,Ltd) អាជ្ញាប័ណ្ណលេខ ០០១/០១១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ និង

១០-ក្រុមហ៊ុន **អិលស៊ីអេចស្កាយ ប្រេសីស មេថល** (LCH SKY PRECIOUS METALS Co.,Ltd ) អាជ្ញាប័ណ្ណលេខ ០០៤/០១៤ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម សាធារណជន ក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធមេត្តាជ្រាបជាព័ត៌មាន និងសហការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧